**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងសណ្ឋាគារ
# វីណាហ្គហ្វ អង្គរ ធូរីហ្សឹម យ៉ញស្តុក ខមភេនី
# ជាមួយនិងតំណាងកម្មករនិយោជិត

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង១០:០០នាទីព្រឹក នៅក្នុង **សណ្ឋាគារ វីណាហ្គហ្វ អង្គរ ធូរីហ្សឹម យ៉ញស្តុក ខមភេនី** មានកិច្ចប្រជុំរវាងអ្នកតំណាងសណ្ឋាគារ ជាមួយនិង អ្នកតំណាងកម្មករនិយោជិត។ នៅក្នុងកិច្ចប្រជុំនេះដែរ អ្នកតំណាងសណ្ឋាគារ បានធ្វើការជូនដំណឹងដល់អ្នកតំណាងកម្មករនិយោជិតទាំងអស់អំពីស្ថានភាពភ្ញៀវទេសចរណ៍ដែលមានការធ្លាក់ចុះមិនទាន់ល្អប្រសើរឡើងវិញ និង អំពីបញ្ហាជំងឺរលាកផ្លូវដង្ហើមខូវីត-១៩ប្រភេទថ្មី (COVID-19) មិនទាន់ស្រាកស្រាន្ត ធ្វើអោយអាជីវកម្មសណ្ឋាគារមិនមានអតិថិជនចូលស្នាក់នៅ។ ដូចនេះ **សណ្ឋាគារ វីណាហ្គហ្វ អង្គរ ធូរីហ្សឹម យ៉ញស្តុក ខមភេនី** យើងខ្ញុំបានសម្រេចជាមួយអ្នកតំណាងកម្មករនិយោជិតទាំងអស់ផ្អាកដំណើរការអាជីវកម្ម និងព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៥នាក់ (ស្រី ០៤នាក់) រយៈពេល០២ខែ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣។

កិច្ចប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង១១:០០នាទីព្រឹកនាថ្ងៃដដែល ដោយភាគីទាំងសងខាងបានចូលរួមប្រកបដោយភាពស្និតស្នាល យោគយល់ និង សហការគ្នាយ៉ាងរលូន។

ដើម្បីជាភស្តុតាងក្នុងការសហការយល់ព្រមទទួលយកសំណើរខាងលើ ដោយមិនប្តឹងទាមទារសំណងផ្សេងៗ និងឆ្លងនូវទុក្ខលំបាក ចូលរួមថែរក្សាសុខភាព អនាម័យ កំចាត់ជំងឺខូវីត-១៩ (COVID-19) ទាំងអស់គ្នា ក្រុមហ៊ុន និងតំណាងនិយោជិតទាំងអស់ សូមផ្តិតមេដៃ ចុះហត្ថលេខា និងត្រាជាសាក្សី។

សៀមរាប ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

**តំណាងប្រធានក្រុមនិយោជិតទាំងអស់**

លោក ង៉ែត ឡុង | លោក សឿន សីត

លោក យឹម សុធី | លោក សេង វិសាល